ក្រសួងយុត្តិធម៌

លេខ ១០១៤ រប-៩៣

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

ព្រះរាជអាជ្ញាអមតុលាការខេត្តបាត់ដំបង
ព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ស្ពឺ
ព្រះរាជអាជ្ញាអមតុលាការខេត្តស្វាយរៀង
ព្រះរាជអាជ្ញាអមតុលាការខេត្តស្ទឹងត្រែង
ព្រះរាជអាជ្ញាអមតុលាការខេត្តកោះកុង
ព្រះរាជអាជ្ញាអមតុលាការខេត្តរតនៈគីរី
ព្រះរាជអាជ្ញាអមតុលាការខេត្តមណ្ឌលគីរី
ព្រះរាជអាជ្ញាអមតុលាការខេត្តព្រះវិហារ
ព្រះរាជអាជ្ញាអមតុលាការខេត្តក្រុងព្រះសីហនុ

**សូមជ្រាប ។**

***កម្មវត្ថុ:*** អំពីរបាយការណ៍ចុះត្រួតពិនិត្យពន្ធនាគារ និងមន្ទីឃុំឃាំងតាមខេត្តក្រុង។

***យោង:*** លិខិតរបស់ក្រសួងលេខ៥០៩រប ចុះថ្ងៃទី១៣-០៩-៩៣ ស្តីពីការណែនាំព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង ពេលចុះត្រួតពិនិត្យពន្ធនាគារ និងមន្ទីឃុំឃាំងតាមខេត្ត ក្រុង។

ក្រសួងបានសង្កេតឃើញថា មានខេត្ត ក្រុង មួយចំនួនរួមទាំងយោធាផង បានចុះធ្វើការត្រួតពិនិត្យពន្ធនាគារ និងមន្ទីរឃុំឃាំងនៅតាមខេត្ត ក្រុង និងអង្គភាពរបស់ខ្លួន តាមខ្លឹមសារលិខិតណែនាំដូចយោងខាងលើហើយសម្រេចបានលទ្ធផលល្អបង្គួរ ព្រមទាំងបានផ្ញើរបាយការណ៍ត្រួតពិនិត្យមកដល់ក្រសួងរៀងរាល់ខែ។ តែដោយឡែកនៅមានខេត្ត ក្រុង មួយចំនួនទៀតដូចរាយខាងលើមកដល់ពេលនេះពុំទាន់បានផ្ញើរបាយការណ៍មកក្រសួងសោះឡើយ ។

ហេតុនេះក្រសួងសូមរំលឹកសាជាថ្មីម្តងទៀត ចំពោះខេត្ត ក្រុង ទាំងអស់ខាងលើអោយផ្ញើរបាយការណ៍ត្រួតពិនិត្យពន្ធនាគារខេត្ត ក្រុង របស់ខ្លួនហើយផ្ញើមកក្រសួងអោយបានទៀងពេលវេលា និងរៀងរាល់ខែទីមួយកុំបីខានសោះឡើយ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៩៣

រដ្ឋមន្ត្រី

**ចែម ស្ងួន**

ចម្លងជូន

ព្រះរាជអាជ្ញាតុលាការគ្រប់ខេត្ត ក្រុង

ដើម្បីជ្រាបនិងអនុវត្ត